# ៣– រឿង មនុស្សខ្ជិលអាចម៍ជិះដំរី
## ខ្ជិលក្ដីឡើងចុងត្នោត(១)

កាលពីព្រេងនាយ មានបុរសម្នាក់ខ្ជិលក្ដី ទៅឡើងចុងត្នោតហើយយកស្លឹកត្នោតចាក់ស្នុក ចាក់ធ្វើរូបសត្វផ្សេង ៗ ហើយគិតថា « អញលក់ស្នុកទាំងអស់នេះ យកប្រាក់ទៅទិញសំលៀកបំពាក់និងទិញក្របីធ្វើស្រែ ហើយនឹងលោះខ្ញុំប្រើ បើកាលណាអញប្រើវាមិនបាន អញនឹងវាយធាក់វា » ថាតែប៉ុណ្ណោះ ក៏យកជើងធាក់ស្នុកនោះ ធាក់មិនគិតគួច ធាក់ទាល់តែភ្លាត់ជើងធ្លាក់ពីលើចុងត្នោត តែបុរសនោះប្រវាចាប់ចុងស្លឹកត្នោតជាប់ ដូចជាគេចងព្យួរតែកតោកនៅនោះ ។ បុរសនោះភ័យណាស់មិនដឹងបើនឹងគណនាឡើយ ។

ពេលនោះ បុរសម្នាក់ទៀតដែលខ្ជិលអាចម៍ ជិះនៅតែលើខ្នងដំរី ក៏បរដំរីនោះទៅ លុះដល់ក្រោមដើមត្នោត បុរសខ្ជិលក្ដីក្រឡេកឃើញ ក៏ស្រែកហៅថា « ឱអ្នកជិះដំរី មេត្តាជួយយកអាយុខ្ញុំផង » ។ បុរសជិះដំរីក្រឡេកឃើញបុរសខ្ជិលក្ដីតោងធាងត្នោតព្យួរខ្លួននៅនោះ ក៏ឆ្លើយតបទៅវិញថា « មិនដឹងជួយដូចម្ដេចទេ » ។ បុរសនៅលើចុងត្នោតថា « អ្នកឯងបរដំរីមកទីខាងក្រោមខ្ញុំ ហើយអ្នកឯងឈរទាញជើងខ្ញុំចុះ » ។ បុរសជិះដំរីឮហើយ ក៏បរដំរីទៅពីខាងក្រោម ក្រោកឈរលើខ្នង

១– ដកស្រង់ពីទស្សនាវដ្ដីកម្ពុជសុរិយា ឆ្នាំ ១៩៣៨ លេខ ៦– ទំព័រ ១៧១

ដីរ លើកដៃប្រវាចាប់ជើង កំពុងតែចាប់ជើង ដីរនោះដូចគេទទាកដេញវា ។ ដើរទៅ ។ បុរសពីរនាក់ក៏នៅព្យួរតែកតោកនៅនោះ ។ បុរសខាងលើភ័យពេក រាកអាចម៍ដាក់ក្បាលបុរសខាងក្រោម ។ បុរសពីរនាក់ភ័យណាស់មិនដឹងធ្វើដូចម្ដេច ។ ក្នុងវេលានោះ មានបុរសទំពែកទាំង៤ នាក់ដើររកស៊ីកាន់ក្ដី លុះដើរទៅដល់កន្លែងនោះ បុរសពីរនាក់ដែលតោងធាងត្នោតនោះ ស្រែកថា « នែលោកទាំង ៤ នាក់ដែលដើរនោះ មេត្តាជួយយកអាយុខ្ញុំផង សឹមខ្ញុំទៅនៅជាខ្ញុំបម្រើលោក » ។ បុរសទំពែក ៤ នាក់ៗ ងើបមើលទៅ ឃើញបុរសពីរនាក់នោះ ក៏ជំនុំគ្នាថា « យើងទាំង ៤ នាក់តាំងពីដើររកស៊ីកាន់ក្ដីមក យូរថ្ងៃ-ខែ-ឆ្នាំហើយមិនដែលបានខ្ញុំប្រើសោះ ឥឡូវយើងគិតយកអាពីរនាក់នេះធ្វើជាខ្ញុំយើង » គិតដូច្នោះហើយ បុរសទាំង ៤ នាក់ដើរចូលទៅក្រោមដើមត្នោត ក៏និយាយថា « យើងមិនដឹងធ្វើម្ដេចទេ » ។ បុរសពីរនាក់ថា « ឱលោកអើយ ! លោកយកសំពត់នោះចងនឹងកលោក ម្នាក់ ១ ជ្រុង ហើយឈរទាញឲ្យតឹងពីក្រោមខ្ញុំ ៗ នឹងទម្លាក់ខ្លួនទៅលើសំពត់នោះ» ។ បុរស ៤ នាក់ ស្ដាប់ហើយក៏ធ្វើតាមពាក្យបុរសពីរនាក់ ស្រេចហើយ បុរសពីរនាក់ទម្លាក់ខ្លួនមកចំសំពត់នោះ ។ ឯបុរសទាំង ៤ ក៏ទង្គិចក្បាលគ្នាស្លាប់អស់ទៅ ។ បុរសពីរនាក់ដឹងថាអ្នកទាំង ៤ នាក់ស្លាប់ហើយ ភ័យណាស់ លុះយប់ មានផ្ទះយាយចាស់ម្នាក់ប្ដីគាត់មិននៅ ទៅធ្វើចង្ការ បុរសពីរនាក់ក៏នាំគ្នាសែងខ្មោចបុរសទំពែកទាំង ៤ យកទៅដាក់នៅរានហាលផ្ទះនោះ ហើយនាំគ្នារត់បាត់ទៅ ។ លុះព្រឹកឡើង យាយចាស់ភ្ញាក់ពីដេកចេញទៅលុបមុខខាងក្រៅ ឃើញខ្មោចនោះហើយ ភ្ញាក់ព្រើតថា "ឃើខ្មោចអ្វីមកស្លាប់នៅនេះ?" ថាហើយក៏អូសខ្មោចនោះមួយម្ដងៗ យកទៅដាក់ក្នុងផ្ទះ ហើយយកខ្មោចនោះមករុំសំពត់ស យកមកដាក់ខាងក្រៅផ្ទះ យំទួញថាប្ដីស្លាប់ ហើយដើរទៅរកអ្នកស្រុកឲ្យគេជួយយកទៅកប់ អ្នកស្រុកមកជួយយកខ្មោចនោះទៅកប់ ហើយត្រឡប់មកផ្ទះវិញ ។ លុះស្អែក ឡើងយាយចាស់ធ្វើដូចមុនទៀត ប្រាប់គេថា "ប្ដីខ្លួនត្រឡប់មកវិញ" ។ អ្នកស្រុកគេក៏ជួយទៀត លុះខានស្អែកឡើង យាយធ្វើយ៉ាងនេះទៀត ទាល់តែគ្រប់ខ្មោចទាំង ៤ ។ អ្នកស្រុកគិតគ្នាថា "យើងទៅវាយខ្មោចនេះ ក្រែងមកទៀត" គិតហើយ

នាំគ្នាទៅចាំនៅផ្លូវដែលយកខ្មោចនោះទៅកប់ ។ លុះព្រលប់ តាប្ដីយាយនោះអស់អង្ករ ត្រឡប់ពីចម្ការមកយកអង្ករស៊ី លីផ្ទាំងមួយផង មកដល់ប្រទះនឹងពួកអ្នកស្រុកដែលគេចាំនោះ គេស្រែកថា « កនយើងមកទៀតហើយ » គេនាំគ្នាដេញវាយតាស្រែកថា « ខ្ញុំទេ ខ្ញុំមកពីចម្ការ » ។ គេថា « អាឯងស្លាប់ទៅហើយមកវិញ ៤-៥ ដងឲ្យតែគេលំបាក » គេក៏វាយតានោះទាល់តែស្លាប់ទៅ ។

## ខ្មើមអាចម៍ជិះដំរី ខ្មើមក្ដីឡើងចុងឈើ

## ប ឆ តំ ណោ ល

កាលនោះភេមាន់អកខ្លា ទន្សាយនោះណា ច្រូតស្បូវបានសព្វគ្រប់ហោង ។ ហើយមកគិតគ្នាអឹងកង ធ្វើម្តេចរួចហោង ដឹកស្បូវទៅផ្ទះយើងណ៎ា ។ ទន្សាយវាឆ្លើយទៅថា មានតែបងខ្លា ខ្លួនគាត់នេះធំល្អណាស់ ។ ភេស្តាប់ទន្សាយឆ្លើយឆ្លាស់ ឆ្លើយថាគួរណាស់ ខ្លាគាត់មាឌធំល្អជា ។ សមនឹងអូសស្បូវយើងប្រា-កដមិនទេណ៎ា ខ្លានោះឥតប្រកែកឡើយ ។ ទើបរករៀបផ្គុកស្បូវហើយ ឥតមានសល់ឡើយ ដាក់លើខ្នងខ្លានោះនៃ ។ អ្នកខ្លះស្រែកទៅថារុ៎ យកចានក្បានថ្មី នូវអស់វែកឆ្នាំងនោះណ៎ា ។ យកមកដាក់លើខ្នងខ្លា ឆាប់ឡើងម្ទីម្នាហើយយកដែកភ្លើងមកផង ។ រៀបស្រេចហើយមកដាក់ហោង សព្វគ្រប់ម៉ត់ម៉ង ឥតមានភ្លេចអ្វីឡើយណ៎ា ។ ករំបិតកាន់ឲ្យគ្រប់គ្នា កណ្តៀវផងរ៉ា យកមកសៀតក្នុងស្បូវហោង ។ រៀបស្រេចមកគិតគ្នាកង បាននរណាហោង នឹងជិះលើខ្នងបងខ្លា ។ អកឆ្លាស់ឆ្លើយទៅវិញថា ឲ្យទន្សាយវា នោះវាគ្រាន់ជាអ្នកបរ ។ ទន្សាយនោះស្តាប់ហើយអរ គេឲ្យអញបរ អញខ្ពិលដើរពេកណាស់ហោង ។ ទន្សាយគិតច្មោះជាម្តង លោតឡើងលើខ្នង ខ្លានោះបរទៅឯងនៃ ។ ទន្សាយបរទៅវៃ ៗ ឆ្វាយបន្តិចនៃ ហើយយកដែកភ្លើងមកវាយ ។ ឮតែច្រឹក ៗ ពព្រាយ ខ្លាសួរទន្សាយ ថារ៉ុបងទន្សាយហ៎ា ។ ឮអ្វីច្រឹក ៗ សោះសា ទន្សាយឆ្លើយថា ចានវារណ្តាំនឹងគ្នា ។ ខ្លាជឿដើរទៅទៀតណ៎ា ទន្សាយនោះវា លួកយកដែក

ភ្លើងពីខ្នង ។ មកវាយទៀតតែបីផង ហើយឆេះជាម្តង ប្រឹងផ្លុំឲ្យវាឆេះឆាប់ ។ ឆេះហើយវាដាក់ទៅផ្អាប់ ខាងស្បូវប្រញាប់ ភ្លើងនោះឆ្លងឆេះឡើងផង ។ ទន្សាយលោតចេញជាម្តង រត់ខ្វាញ់ទៅហោង ទៅឡើងលើដើមសង្ក្យ៉រ ។ ផ្សារដោយខ្លួនភិតញញ័រ ឡើងទៅទទ័រ បេះផ្លែសង្ក្យ៉រស៊ីហោង ។ ឯខ្លា នោះខ្វាំងកន្លង ឆលវាក្តៅខ្នង រលាស់ខ្ញាត់ខ្ញាយចេញណា ។ ឯខ្នងរលាកក្តៅផ្សា ចាប់ពើតពេកណា ស្រែកញរលូងទាំងព្រៃ ។ ក្នុងចិត្តខឹងណាស់ពេកក្រៃ នឹងទន្សាយនៃ ខំរត់ទាំងឈឺតាមទៅ ។ វាស្រែករលូងពេកកូវ ខំរត់តាមទៅ ទាន់ទន្សាយនៅសង្ក្យ៉រ ។ ផ្សារដោយចិត្តខឹងញញ័រ ទទឹទទ័រ ថាអើអានៅនេះហើយ ។ អញស៊ីក្បាលអាឲ្យស្បើយ ចិត្តអញខឹងហើយ ឥឡូវនេះឯងហោងណ៎ា ។ អាចោរដកទងប៉ៃអា អញរកទេណ៎ា ឥឡូវអញឃើញហើយនៃ ។ អញចាប់កាច់កឲ្យក្ស័យ ជីវិតហើយនៃ សឹមអញទំពារលេបណ៎ា ។ ទន្សាយស្តាប់ហើយឆ្លើយថា ជេរថាប៉ៃអា ដកទងចង្រៃចោរលាញ ។ អញ្ជើញអាមកចាប់ទាញ អញទៅអម្បាញ បើថាខ្លួនអាមិនស្លាប់ ។ ទេពតាលោកចុះមកប្រាប់ ឲ្យអញឡើងចាប់ បូតស្លឹកសង្ក្យ៉រស៊ីហោង ។ អញ្ជើញអាមកចាប់លង មិនក្រែងជាម្តង លោកជាទេពតានោះនៃ ។ បើអាមិនមានទុក្ខភ័យ លុះដល់ខ្លួនក្ស័យ ជាងភ្លើងរលាកនោះណ៎ា ។ ក្រែងមិនជឿអញលងអា ចាប់អញស៊ីជា អាហារអានោះឯងនៃ ។ បើអាមិនមានទុក្ខភ័យ ស្លាប់ហើយធ្លាក់ឮ នរកធ្ងន់ជ្រៅក្តាត់ណ៎ា ។ ខ្លាស្តាប់ទន្សាយចរចា ហាក់មែនដូចថា លោមវាម្តងនេះឯងនៃ ។ ក្សិណនោះឯខ្លាស្រដី ថានែលេងអ្វី ទន្សាយអញចូលលេងផង ។ ទន្សាយស្តាប់ដាក់ហើយហោង អញនៅជាម្តង អានឹងមកស៊ីអញណ៎ា ។ ខ្លាស្តាប់ហើយឆ្លើយទេអា អញហ៊ានស្បថណ៎ា កុំឲ្យព្រះប្រោសអញហោង ។ ទន្សាយជឿខ្លាកន្លង ថាបើច្នោះហោង បងឯងឡើងមកប្រញាប់ ។ បើបងឡើងមកចង់ស- ប្បាយបងបូតចាប់ អំពិតលំឡើងខ្វាំងក្លា ។ ទន្សាយចង្កាប់

នោះណ៎ា វាយល់បន្ទា សង្ស័យនោះកោងចុះខ្ញី ។ ទើបឯទន្សាយនោះនៃ ប្រឹង
ប្រែងជើងដៃ លោតចុះបើកខ្លាឡើងទៅ ។ ទន្សាយរត់ទៅសំដៅ ពានលើវល្លិ
នៅ វល្លិនោះជាទោងល្អក្រៃ ។ ឃើញហើយឡើងតាប់វៃ។ អង្គុយលើនៃ
ហើយវាយោលជាទោងលេង ។ ឯខ្លានោះនៅតែឯង ឥតកោតឥតក្រែង បួត
ស្ងឹកសង្ស័យលេងហោង ។ ទើបខ្លាក្ដាប់ខ្ជាប់ជាម្លួង បួតពីដើមហោង វាមុតដៃ
នោះអស់ណ៎ា ។ ចាប់ពើតបង្កើតឈឺផ្សា លោតចុះដេញអា ទន្សាយរត់ខ្ជាញ់
ទៀតទៅ ។ ដល់ឃើញទន្សាយនោះនៅ លើវល្លិនោះក្ដួរ ថាអា ៗ នៅនេះ
ហើយ ។ អាបញ្ឆោតអញព្រងើយ អាអកកន្ដើយ នៅនេះទេណ៎ាឯងនៃ ។
អញដើររកអាពេកក្រៃ ឥឡូវនេះនៃ ប្រទះនឹងអាហើយហោង ។ ទន្សាយស្ដាប់
ឃើញឆ្លើយស្នង ជេរវិញរំពង ថាអាធ្វើប្ញូអាចម៍អញ ។ ទេពតាទេព្រក្សស្រឡាញ់
អញណ៎ាទើបអញ លោកឲ្យអញយោលទោងលេង ។ លោកយល់អញចេះកំប្លែង
លោកឲ្យអញលេង លោកនឹងប្រើង់ព្រះសណ្ដាប់ ។ រីឯអាខ្លានោះស្ដាប់ ជាក់ហើយ
ក្រឡាប់ រំសាយអស់ខឹងនោះចេញ ។ អង្វរទន្សាយនោះវិញ ទន្សាយឲ្យអញ
យោលទោងលលេងផងរ៉ា ។ ទន្សាយថាអញឆោតណ៎ា អានឹងទំពា ក្បាលអញ
ឥឡូវនេះឯង ។ ខ្លាថារ៉ុអើយកុំក្រែង អញស្បថឲ្យឯង កុំឯងបារម្ភឡើយណ៎ា ។
ទន្សាយបានស្ដាប់ជៀក្រា- កដហើយថាអា ឡើងមកយោលលេងចុះហោង ។
អញប្រាប់បងឯងជាម្លួង បងមកយោលលង បងយោលឲ្យខ្លាំងសោះសា ។ នោះ
ទើបលោកទេពតា រីងចូលចិត្តជា ស្រឡាញ់បងឯងពេកក្រៃ ។ ទន្សាយថាច្នោះវៃ។
ចុះមកដល់ដី ហើយខ្លាឡើងទៅយោលហោង ។ ទន្សាយរត់ខ្ជាញ់ជាម្លួង ឆ្ងាយ
ក្រៃកន្ទង ឃើញឫស្សីសង្កៀតគ្នា ។